**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២១ រវាង លោកស្រី លឹម គៀត កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៤០១៥៧០ (០១) ដែលមានតួនាទី **ប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន** និងជាតំណាងភាគីនិយោជកនៃសាខាក្រុមហ៊ុន **អេច ជី ប៊ី ហ្វ៊ូដ អ៊ិនដាស្ទ្រី "ដូនពេញ"** ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ #២៧ ផ្លូវ ២១៤ កែងផ្លូវ ៥១ សង្កាត់ បឹងរាំង ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

និង

លោក ណូយ បូរី កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១០០៩២៩៧៤០ ដែលមានតួនាទីជា **មេផ្នែកចុងភៅ** លោកស្រី ម៉ា សីហា កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៣៥២៧៤៧ (០១) មានតួនាទីជា **ចុងភៅ** លោក ខូវ ផៃលាភ កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១៦០៤២៤៩៩៨ មានតួនាទីជា **ចុងភៅ** លោក រឿង បញ្ញា កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០២០៨១៩២៦២ (០១) មានតួនាទីជា **បុគ្គលិកផ្នែកភេសជ្ជៈ** ជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

H G B FOOD INDUSTRY Co., Ltd. KINGDOM OF CAMBODIA

១- <u>រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖</u>

ការព្យួរកិច្ចសន្យាការងារមានចំនួនកម្មករនិយោជិកចំនួន៣២នាក់ (ស្រី ១៨នាក់) ចាប់ពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២១ ដល់ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០២១ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ-១៩។

២- <u>ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖</u>

ភាគីនិយោជិក នឹងទទួលបានប្រាក់ឧបត្ថម្ភ៣០ដុល្លាអាមេរិក កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មានសិទ្ធិក្នុងការស្នើសុំបញ្ចប់កិច្ចសន្យាការងារជាមួយភាគីនិយោជក ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះបាន។

៣- <u>កាលបរិច្ឆេទចូលបម្រើការងារវិញ៖</u>

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញបន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២១

| តំណាងភាគីនិយោជិក | | | | តំណាងភាគីនិយោជក |
| --- | --- | --- | --- | --- |
| លោក ណូយ បូរី | លោកស្រី ម៉ា សីហា | លោក ខូវ ផៃលាភ | លោក រៀង បញ្ញា | លោកស្រី លឹម គៀត |

H G B FOOD INDUSTRY Co., Ltd.
KINGDOM OF CAMBODIA